**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៦២៧ សសរ

# សេចក្តីសម្រេច

## ស្តីពី

## ការកែសម្រួលសមាជិកក្រុមការងារថ្នាក់ជាតិ ចុះមូលដ្ឋាន ដើម្បីត្រួតពិនិត្យ និងគាំទ្រការអនុវត្តកម្មវិធី នយោបាយនិងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ របស់រាជរដ្ឋាភិបាលកម្ពុជា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២ នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- យោងសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាលស្តីពីការបង្កើតក្រុមការងារថ្នាក់ជាតិចុះមូលដ្ឋាន ដើម្បីត្រួតពិនិត្យនិងគាំទ្រការអនុវត្តកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣របស់រាជរដ្ឋាភិបាលកម្ពុជា
- យោងសេចក្តីណែនាំរបស់រាជរដ្ឋាភិបាលកម្ពុជាលេខ ០១ សណន ចុះថ្ងៃទី២៧ ខែមករា ឆ្នាំ២០១៤ ស្តីពីតួនាទី ភារកិច្ច និងរបៀបរបបការងារសម្រាប់ក្រុមការងារចុះបំពេញបេសកកម្ម តាមមូលដ្ឋាន ដើម្បីត្រួតពិនិត្យ និង គាំទ្រការអនុវត្តកម្មវិធីនយោបាយ និង យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ របស់រាជរដ្ឋាភិបាលកម្ពុជា
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

**ប្រការ១.-**

ត្រូវបានផ្លាស់ប្តូរសមាជិកក្រុមការងារថ្នាក់ជាតិចុះមូលដ្ឋាន ដើម្បីត្រួតពិនិត្យ និងគាំទ្រការអនុវត្តកម្មវិធីនយោបាយ និង យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ របស់រាជរដ្ឋាភិបាលកម្ពុជា នៅខេត្តមួយចំនួនដូចខាងក្រោម៖

| | |
|---|---|
| ១-លោកជំទាវ **តឹក ច័តកំរ៉ែង** | រដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម ពីសមាជិកក្រុមការងារថ្នាក់ជាតិ ខេត្តសៀមរាប មកជាសមាជិកក្រុមការងារថ្នាក់ជាតិខេត្តកណ្តាល។ |
| ២-ឯកឧត្តម **គឹម ស៊ីថន** | រដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម កែសម្រួលពីសមាជិកក្រុមការងារថ្នាក់ជាតិខេត្តកណ្តាល រក្សាទុកជាសមាជិកក្រុមការងារថ្នាក់ជាតិខេត្តព្រះសីហនុ។ |
| ២-ឯកឧត្តម **អ៊ុក ប្រាថ្នា** | រដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម ពីអនុប្រធានក្រុមការងារថ្នាក់ជាតិខេត្តប៉ៃលិន មកជាសមាជិកក្រុមការងារថ្នាក់ជាតិខេត្តកំពង់ឆ្នាំង។ |

**ប្រការ២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសាមី រដ្ឋបាលខេត្ត និងសាមីខ្លួនដូចមានចែងក្នុងប្រការ១ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ ឲ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០១ ខែ៧ ឆ្នាំ២០១៥

**តប.នាយករដ្ឋមន្ត្រី**
**ឧបនាយករដ្ឋមន្ត្រី**

**សម្តេចក្រឡាហោម ស ខេង**

*កន្លែងទទួល:*

*-ក្រសួងព្រះបរមរាជវាំង*
*-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
*-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
*-អគ្គលេខាធិការដ្ឋានរដ្ឋសភា*
*-អគ្គលេខាធិការរាជរដ្ឋាភិបាល*
*-ខុទ្ទកាល័យ សម្តេចនាយករដ្ឋមន្ត្រី*
*-ខុទ្ទកាល័យ សម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី*
*-រាជកិច្ច*
*-ឯកសារ-កាលប្បវត្តិ*